ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៣-០២-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣៦ ស្តីពីការលើកលែងទោសអោយទណ្ឌិតឈ្មោះ នួច សុវណ្ណ ៣៤៣


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


២៦-០២-២០០៤ -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពីការបង្កើតអនុគណៈកម្មាធិការផែនការ អភិវឌ្ឍន៍អាង ទន្លេមេគង្គ ៣៤៤

២៧-០២-២០០៤ -អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានអ៊ិនធីវេជ ៣៤៨

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥១

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥២

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការជូនមេដាយសេរ្ថាបនាជាតិ ៣៥៣

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៤

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥៥

២៥-០២-២០០៤ -អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៥៦

២៦-០២-២០០៤ -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៦១

២៦-០២-២០០៤ -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៦៣


### ២. សេចក្តីសំរេច


២៤-០២-២០០៤ -សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការប្រគល់សិទ្ធិ ៣៦៤

២៥-០២-២០០៤ -សេចក្តីសំរេចលេខ ០៩ សសរ ស្តីពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ៣៦៥

២៧-០២-២០០៤ -សេចក្តីសំរេចលេខ ១០ សសរ ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់ឆ្នេរសមុទ្រ ក្រុង ព្រះសីហនុ ៣៧០


### ៣. សារាចរណែនាំ


២៥-០២-២០០៤ -សារាចរណែនាំលេខ ០១ សរណន ស្តីពីការអនុញ្ញាតអោយរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទដឹកភ្ញៀវទេសចរបរទេសចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ៣៧២


## III. ការិយាល័យក្រសួង

### ១. ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ

### ក្រុមប្រឹក្សាគោលនយោបាយដីធ្លី


២៤-០២-២០០៤ -សេចក្តីសំរេចលេខ ០០១ សសរ ស្តីពី ក្រុមការងារគ្រប់គ្រងដីរដ្ឋ ៣៧៥

## ២-និស្ស័ការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៧-០២-២០០៤ -ប្រកាសលេខ ០៦០ MOC/M 2004 ស្ដីពីលទ្ធផល នៃការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀក បំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុង ឆ្នាំ ២០០៤ ៣៧៨

## ៣-និស្ស័ការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

២៤-០២-២០០៤ -សេចក្ដីណែនាំ លេខ ០៤ សណេន ស្ដីពីការរៀបចំល្បែងប្រជាប្រិយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ឆ្នាំវក ឆស័ក ពុទ្ធសករាជ ២៥៤៨ ត្រូវនឹងថ្ងៃទី ១៣-១៤-១៥ ខែ មេសា ឆ្នាំ ២១០០៤ ដើម្បី ទាក់ទាញ និងបំរើដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ៣៨៣

## ៤-និស្ស័ការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២៣-០២-២០០៤ -ប្រកាសលេខ ៧៣ ក.ធ.ស.ប្រក ស្ដីពីការបង្កើតថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិក វិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម ៣៨៥

## ៥-អន្តរក្រសួង ក្រសួងយុត្តិធម៌ និង ក្រសួងពាណិជ្ជកម្ម

២៧-០២-២០០៤ -ប្រកាសរួម លេខ ០១ ប្រក.កយ.ពណ ២០០៤ ស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិត ដោះស្រាយបទល្មើសស្ដីពីគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ដល់មន្ត្រីនគរបាល យុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម ៣៨៦

# ព្រះរាជក្រឹត្យ

នស/រកត/០២០៤/០៣៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលើកលែងទោសអោយទណ្ឌិតឈ្មោះ **ឌូច សុចណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ តាមអំណាចសាលដីកាលេខ ៣២ " ឈ " ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៧៤.០៤.០២.០៣៦ លេខ: ២៥.ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាវី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០២៣ អនក្រ. បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតអនុគណៈកម្មាធិការ**

**ផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៣/២៦៦ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៣ ស្តីពីការកែសំរួល និងតែងតាំងសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកស/០៩០៣/២៨២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការសំរួល និងតែងតាំងសមាជិកក្រុមប្រឹក្សា និងគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គតំណាងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ-បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- តាមសំណូមពរចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១.-**

បង្កើតអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សំរាប់ការកសាង និងការអនុវត្តកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**មាត្រា ២.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានសមាសភាពដូចតទៅ:

១. សមាជិកគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ តំណាងអោយប្រទេសកម្ពុជា..... ..........ប្រធាន

២. អគ្គនាយកនៃក្រសួងផែនការ..........អនុប្រធាន

៣. អគ្គនាយក ទទួលបន្ទុកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម.......... ..........អនុប្រធាន

៤. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងសាធារណការ និងដឹកជញ្ជូន....សមាជិក

៥. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងបរិស្ថាន..........សមាជិក

៦. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..........សមាជិក

៧. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ..........សមាជិក

៨. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល.......... ..........សមាជិក

៩. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់..........សមាជិក

១០. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងអភិវឌ្ឍន៍ជនបទ..........សមាជិក

១១. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងទេសចរណ៍..........សមាជិក

១២. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងមហាផ្ទៃ..........សមាជិក

១៣. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន.......... ..........សមាជិក

១៤. អគ្គនាយក ទទួលបន្ទុកកិច្ចការផែនការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ..........សមាជិក

**មាត្រា ៣.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គមានភារកិច្ចដូចតទៅ:

- ពិនិត្យឡើងវិញ និងអនុម័តលើផែនការការងារ របាយការណ៍នៃដំណើរវិវឌ្ឍន៍ និងឯកសារដទៃទៀតដែលទាក់ទងការកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ អោយស្របទៅនឹងកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ទិសដៅ និងនីតិវិធីអភិវឌ្ឍន៍អាងទន្លេមេគង្គរបស់ជាតិ

- សំរបសំរួលជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងដោយឡែកជាមួយអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដើម្បីធានាបានថារាល់សកម្មភាពការងារទាំងឡាយ ស្របគ្នាជាមួយនឹងបណ្តាសកម្មភាពការងារដែលកំពុងអនុវត្តក្នុងប្រទេសនៅតាមដងទន្លេមេគង្គ

- សំរួលដល់កិច្ចសហការរវាងអន្តរស្ថាប័ន និងការកៀរគរធនធានដែលជាតំរូវការរបស់ជាតិ សំរាប់អោយការកសាងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គមានដំណើរការទៅមុខ

- ពិនិត្យតាមដាន និងវាយតំលៃលើការវិវឌ្ឍនៃការកសាង និងការអនុវត្តគំរោងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ រួមមានការធ្វើសេចក្តីសំរេចចិត្តនានា និងការជំរុញការអនុវត្តអោយបានទាន់ពេលវេលា

- ធ្វើរបាយការណ៍ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អំពីការវិវឌ្ឍនៃការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងដោយឡែកអំពីបញ្ហានានាដែលពាក់ព័ន្ធការអភិវឌ្ឍអាងទន្លេមេគង្គរបស់ជាតិ ដែលតំរូវអោយមានការពិនិត្យ និងពិចារណាបន្ថែម

- លើកសំណើជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា លើការចាត់តាំង ការផ្លាស់ប្តូរសមាសភាពអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងក្រុមការងារផ្សេងៗទៀតរបស់ជាតិសំរាប់ការអនុវត្តកម្មវិធីផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ

- ពិនិត្យ និងអនុម័តលើលក្ខខណ្ឌការងាររបស់អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គនិងក្រុមការងារផ្សេងៗទៀតរបស់ជាតិ ដើម្បីដាក់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាពិនិត្យ និងសំរេច

- ផ្តល់ការណែនាំដល់អង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ និងអនុសាសន៍នានាដែលទាក់ទងនឹងផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដល់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

- ធ្វើការវាយតំលៃ និងអនុម័តលើសមាហរណកម្មគំរោង ឬកម្មវិធីថ្នាក់ជាតិដែលស្នើឡើងដោយអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដើម្បីដាក់ជូនប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាពិនិត្យ និងសំរេច ។

**មាត្រា ៤.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គជាសេនាធិការ ស្ថិតនៅក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសំរបសំរួលផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ត្រូវបង្កើតឡើងដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ត្រូវធ្វើការប្រជុំសាមញ្ញ បី(០៣)ដង យ៉ាងតិចក្នុងមួយឆ្នាំ និងការប្រជុំវិសាមញ្ញតាមតំរូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**មាត្រា ៦.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រធានស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ថ្នាក់ និងសមាជិកអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ , ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

**លឹម គានហោ**

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ វិទ្យាស្ថានអ៊ីនធើរេដ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈ វិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតរបស់លោក វិបុល នារាយណ៍ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៣
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១** : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថាន អ៊ីនធើរេដ InterEd Institute** ហៅកាត់ជាភាសាខ្មែរ "វ.អ" និង ហៅកាត់ជាភាសាអង់គ្លេស " I.I " ។ វិទ្យាស្ថាន

អ៊ិនធីវេជ មានទីតាំងស្ថិតនៅអោគារប្រផេះ ប្លុក A ជាន់ទី ៥ ផ្លូវព្រះស៊ីហនុ (២៧៤) កែងនឹងផ្លូវ សម្តេចសុធារស ( ៣ ) សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : វិទ្យាស្ថាន អ៊ិនធីវេជ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : វិទ្យាស្ថាន អ៊ិនធីវេជ ធ្វើការបណ្តុះបណ្តាលថ្នាក់ :

- បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ
- បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ
- ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ និង
- បណ្ឌិត សិក្សាស្រាវជ្រាវរយៈពេលយ៉ាងតិច ៣ ឆ្នាំ ។

វិទ្យាស្ថានអ៊ិនធីវេជ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជននិងកីឡា។

មាត្រា ៤ : វិទ្យាស្ថាន អ៊ិនធីវេជ មានមហាវិទ្យាល័យ :

១. មហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសា

២. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម ។

នៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : វិទ្យាស្ថាន អ៊ិនធីវេជ មានក្រុមប្រឹក្សាភិបាលមួយ សំរាប់ពិនិត្យសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ និង អនុម័តលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : ក្នុងលក្ខខណ្ឌទទួលសិស្ស-និស្សិតអោយចូលរៀន វិទ្យាស្ថាន អ៊ិនធីវេជ ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពី ការជ្រើសរើស និស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៧ : នាយក នៃវិទ្យាស្ថាន អ៊ិនធីវេជ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន សាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវការងារសិក្សា ការងារស្រាវជ្រាវ ការប្រលង និងការប្រគល់សញ្ញាប័ត្រ ។
- គោរព និងអនុវត្តតាម សារាចរ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

មាត្រា ៨ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានអ៊ិនធីវេជ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិតនិងតាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយវិទ្យាស្ថានអ៊ិនធីវេជ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញនិងអនុវត្តបាន តាមគោលការណ៍កំណត់របស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានអ៊ីនធីវេដ មានភារកិច្ចអនុវត្ត និងប្រតិបត្តិ តាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ១២ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនដំណឹង"
- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តសៀមរាប

## សំ រេ ច

**មាត្រា ១** ៖ ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០២ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០២ រូប ដែលបានរួមចំណែកកសាងមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប និង ជួយឧបត្ថម្ភថវិកាជាប្រចាំដល់គ្រប់សកម្មភាព ធ្វើអោយមន្ទីរពេទ្យនេះដំណើរការទៅបានល្អ ដូចមានរាយព្រះនាម និង នាមខាងក្រោម ៖

១-ព្រះតេជគុណ **Houmyo Saito**

២-លោក វេជ្ជបណ្ឌិត **Masumi Kamachi**

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

### សំ រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក មូ សុភាព ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជននៅសហរដ្ឋអាមេរិក ចំនួន ០៧រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ស្ពានល្វា កុដិចំនួន០២ខ្នង សាលាធម្មសភា និង ជួសជុលព្រះវិហារ នៅក្នុងវត្ត*ដង្កោ* និង វត្ត*ល្វា* ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយ ព្រះនាម និង នាមខាង ក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | |
|---|---|
| ១-ព្រះតេជគុណ **សោម សុភា** | បច្ច័យ ចំនួន ១១.៧៧៨ ដុល្លារ |
| ២-លោក **ស៊ិន កែវជាតិ** | ថវិកា ចំនួន ២៩.៤០០ ដុល្លារ |
| ៣-អ្នកស្រី **មួន ម៉ុត** | ថវិកា ចំនួន ១៧.០៤៥ ដុល្លារ |

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | |
|---|---|
| ១-លោក **ឌី សុផល** និងអ្នកស្រី **សាត ហួយ** | ថវិកា ចំនួន ៤.៥០០ ដុល្លារ |
| ២-លោក **ឆេង លួន** និងអ្នកស្រី **ខាន់ យ៉ុម** | ថវិកា ចំនួន ៣.០០០ ដុល្លារ |
| ៣-លោក **ទីក ទួយ** និងអ្នកស្រី **យ៉ាំ លួយខូ** | ថវិកា ចំនួន ១.៥៥២ ដុល្លារ |
| ៤-លោក **រ៉ន ពេក** និង អ្នកស្រី **សំអាត** | ថវិកា ចំនួន ១.០២៦ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

155

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០៩រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងព្រះវិហារ កុដិ ក្លោងទ្វារ និង សមិទ្ធផលជាច្រើនទៀត នៅក្នុងវត្ត *ជ្រៃ* ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **ហែម នុំ** ព្រះចៅអធិការ វត្តជ្រៃ បច្ច័យ ចំនួន ១១.៦៧៤.៦៥ ដុល្លារ

២-លោក **កើត សុខរិទ្ធិ** និងភរិយា សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៤៧.០៧៧ ដុល្លារ

៣-លោក **ឈុន លីម** និងភរិយា សប្បុរសជននៅក្នុងប្រទេស ថវិកា ចំនួន ៤១.៨៧៣ ដុល្លារ

៤-លោក **អៀម យុនណនាថុន** និងភរិយា សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៥.៦៧២ ដុល្លារ

៥-លោក **ហោន ប៊ួយ** និងភរិយា សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១១.៧៧២ ដុល្លារ

៦-លោក **ខិន សារូ** និងភរិយា សប្បុរសជននៅក្នុងប្រទេស ថវិកា ចំនួន ១១.៧២៧ ដុល្លារ

៧-លោកយាយ **ម៉ក់ សារី** និងក្រុមគ្រួសារ សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១១.៦៧២ ដុល្លារ

៨-លោកយាយ **ហេខ ម៉ុម** និងបុត្រ សប្បុរសជននៅសហរដ្ឋអារមេរិក ថវិកា ចំនួន ១១.៥២២ ដុល្លារ

៩-លោក **វ៉ែណ គីមសុន** និងភរិយា សប្បុរសជននៅក្នុងប្រទេស ថវិកា ចំនួន ១០.៨១៩.៥៥ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

152

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីរាជការ ចំនួន ០៥ រូប ដែលមាន ស្នាដៃល្អ ក្នុងការបំពេញការងារ ជួយកសាង និង អភិវឌ្ឍន៍ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយ នាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឯកឧត្តម | **សំកុល សុខន** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និង ជាប្រធាននាយកដ្ឋានពន្ធនាគារ |
| ២-ឯកឧត្តម | **ឯម សំណាង** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និង ជាប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៣-ឯកឧត្តម | **ស៉ំ នីមសារុន** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និង ជាអនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៤-ឯកឧត្តម | **ហ៊ីវ សុវណ្ណ** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និង ជាអនុប្រធានទី១ រតនាគារជាតិ |
| ៥-លោក | **សោម ខាន់ជា** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

106

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ១៥៦ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជួយកសាង និង អភិវឌ្ឍន៍ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-ឯកឧត្តម | **ឌិន ចាយ** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភាជាតិ និង ជាអនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ២-ឧត្តមសេនីយ៍ត្រី | **ថោង លឹម** | អនុប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៣-វរសេនីយ៍ឯក | **ហួរ ឧត្តមុន្នី** | ជំនួយការឯកឧត្តម ស ខេង សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ |
| ៤-វរសេនីយ៍ឯក | **ឌួច ឌឹម** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ៥-វរសេនីយ៍ឯក | **ទ៉េង សុធី** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ៦-វរសេនីយ៍ឯក | **អ៊ិន បូរ៉ា** | អនុប្រធាននាយកដ្ឋាន នគរបាលព្រហ្មទ័ណ្ឌ |
| ៧-វរសេនីយ៍ឯក | **ឆែន បូរ៉ានី** | អនុប្រធាននាយកដ្ឋាន នគរបាលព្រហ្មទ័ណ្ឌ |
| ៨-លោក | **ស៊ុន សុវណ្ណារិទ្ធ** | អនុប្រធាននាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៩-លោក | **ឃាក់ វ៉ាត** | អនុប្រធាននាយកដ្ឋាន ពន្ធនាគារ |
| ១០-លោក | **ឌិន លី** | អនុប្រធាននាយកដ្ឋាន ពន្ធនាគារ |
| ១១-វរសេនីយ៍ទោ | **វ៉េន សុគា** | ស្នងការរង នគរបាល ខេត្តពោធិសាត់ |
| ១២-វរសេនីយ៍ទោ | **គង់ សុជាតិ** | នាយការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ១៣-វរសេនីយ៍ទោ | **សុខ សារ៉ែត** | នាយការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ១៤-វរសេនីយ៍ទោ | **កែវ តារាពេជ្យ** | នាយការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ១៥-លោក | **អ៊ុយ ស៊ុន** | នាយការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

១៦-វរសេនីយ៍ទោ **ឆាម ម៉ុនសេង** នាយការិយាល័យ នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គិភ័យ

១៧ លោក **អ៊ុ ឈាង** ប្រធានការិយាល័យ ឃ្លាំងបេឡា រតនាគារជាតិ

១៨-លោក **ស្រី សាមិត្ត** ប្រធានការិយាល័យគណនីប្រាក់បញ្ញើ រតនាគារជាតិ

១៩-លោក **ប៉ែន ចាន់លី** ប្រធានការិយាល័យសិក្សាស្រាវជ្រាវ រតនាគារជាតិ

២០-លោកស្រី **អ៊ុំ សុជាតិ** ប្រធានការិយាល័យ ចំណាយថវិកាជាតិ

២១-លោក **កែ ម៉ុនឡេង** ប្រធានរតនាគារ រាជធានីភ្នំពេញ

២២-លោក **យឹម សេងគ្រី** អនុប្រធានរតនាគារ រាជធានីភ្នំពេញ

២៣-វរសេនីយ៍ត្រី **ពៅ សារិន** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៤-វរសេនីយ៍ត្រី **គិន ពេជ** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៥-លោក **គីម សារិន** ប្រធានមណ្ឌលអប់រំកែប្រែព្រៃស ទី១ នាយកដ្ឋានពន្ធនាគារ

២៦-លោក **នង កាប៉ូរ៉ា** ប្រធានមណ្ឌលអប់រំកែប្រែព្រៃស ទី២ នាយកដ្ឋានពន្ធនាគារ

២៧-លោក **មួង សំអាត** ប្រធានពន្ធនាគារ ខេត្តកណ្ដាល

២៨-លោក **ខន សរ** ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សូរិយោដី

២៩-លោក **នុច សំអឿន** អនុប្រធានមន្ទីរអប់រំ ខេត្តកណ្ដាល

៣០-លោក **ម៉ុន ថេង** អភិបាលស្រុកកណ្ដាលស្ទឹង

៣១-លោក **បូរ ណារ៉ែត** អភិបាលរងស្រុកកណ្ដាលស្ទឹង

៣២-លោក **ជុំ សារឿន** អភិបាលរងស្រុកកណ្ដាលស្ទឹង

៣៣-លោក **ញ៉ិល ឈឿន** មន្ត្រីស្រុកកណ្ដាលស្ទឹង

**ខ. មេដាយប្រាក់ការងារ :**

១-វរសេនីយ៍ឯក **ឡឹក វណ្ណៈ** អនុប្រធាននាយកដ្ឋាន នគរបាលព្រហ្មទណ្ឌ

២-វរសេនីយ៍ទោ **ភ្លាំ ចុត្ថា** នាយការិយាល័យ នាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន

៣-វរសេនីយ៍ទោ **ឃួន សុផន** ជំនួយការ នាយកដ្ឋាន កណ្ដាលយុត្តិធម៌

៤-វរសេនីយ៍ទោ **ម៉ៅ តារា** នាយការិយាល័យ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៥-វរសេនីយ៍ទោ **ស៊ៀង អុន** នាយការិយាល័យ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៦-វរសេនីយ៍ទោ **សោម បូរ៉ា** នាយការិយាល័យ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៧-វរសេនីយ៍ទោ **ស៊ិន ជុំហ៊ី** នាយការិយាល័យ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៨-វរសេនីយ៍ទោ **កើត ម៉ុណ្ណា** នាយការិយាល័យ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

៩-វរសេនីយ៍ត្រី **អ៊ុក សុខុម** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១០-វរសេនីយ៍ត្រី **អ៊ាំង ប៊ុលីន** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១១-វរសេនីយ៍ត្រី **ឈុល ផាវី** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១២-វរសេនីយ៍ត្រី **គីម ម៉េងឈាង** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-វរសេនីយ៍ត្រី **នូ ឡឿន** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៤-វរសេនីយ៍ត្រី **ម៉ៅ ម៉ុន** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៥-លោកស្រីវរសេនីយ៍ត្រី **តាន់ សុគមង្គល** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៦-វរសេនីយ៍ត្រី **យ៉ាន សារឿន** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-វរសេនីយ៍ត្រី **ឈឹម គា** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៨-វរសេនីយ៍ត្រី **យាន ឆាង** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៩-លោក **ជុំ រដ្ឋរិទ្ធ** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២០-លោក **គីម តារា** នាយរងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២១-លោក ញ៉ាញ់ ដានី នាយករងការិយាល័យ នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២២-វរសេនីយ៍ត្រី អ៊ុំ ទណ្ណៈ នាយករងការិយាល័យ នាយកដ្ឋាន នគរបាលព្រហ្មទណ្ឌ
២៣-វរសេនីយ៍ត្រី ឆែន បូរត្ន នាយករងការិយាល័យ នាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
២៤-អនុសេនីយ៍ឯក សេម សឿន នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២៥-អនុសេនីយ៍ឯក ឆេស ដល្លា នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២៦-អនុសេនីយ៍ឯក ម៉ុក សំអុល នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២៧-អនុសេនីយ៍ឯក សៀង សាន នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២៨-អនុសេនីយ៍ឯក នួន ធី នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
២៩-អនុសេនីយ៍ឯក រ៉ិន ចន្ទី នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣០-អ្នកស្រីអនុសេនីយ៍ឯក ពុធ ទុន្នី នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣១-កញ្ញាអនុសេនីយ៍ឯក ចិន សំអាង នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣២-អនុសេនីយ៍ឯក វណ្ណ ចាន់ណោ នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៣-អនុសេនីយ៍ឯក ថោង សុផាត នាយផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៤-អនុសេនីយ៍ឯក រិន សារឿន នាយផ្នែក នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន
៣៥-អនុសេនីយ៍ទោ ឃឹល មិន នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៦-អនុសេនីយ៍ទោ ជា សុគន្ធា នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៧-អនុសេនីយ៍ទោ ជុំ អ៊ីម នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៨-អនុសេនីយ៍ទោ ជាស លឹម នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៣៩-អនុសេនីយ៍ទោ នួច រ៉ាមី នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤០-អនុសេនីយ៍ទោ គីម ដាណារ៉ាត់ នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤១-អនុសេនីយ៍ទោ មិន សុខុម នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤២-អនុសេនីយ៍ទោ ម៉ែន មេន នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤៣-អនុសេនីយ៍ទោ តាំង នៃស្មួង នាយរងផ្នែក នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤៤-អនុសេនីយ៍ទោ ប្រាប ផាន នាយរងផ្នែក នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន
៤៥-អនុសេនីយ៍ទោ ជា សុផល នាយរងផ្នែក នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន
៤៦-កញ្ញាអនុសេនីយ៍ត្រី ណុប សំភ័ណ្ឌ មន្ត្រី នាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៤៧-លោក អ៊ុច ចាន់ណារ៉ា មន្ត្រី អគ្គលេខាធិការដ្ឋាន
៤៨-លោក គឹម ជួន ប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៤៩-លោក ម៉ៅ ណាំ ប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥០-លោក សារ៉េម នី ប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥១-លោក ឈឹម ធីតា អនុប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥២-លោក សួន ទុន្នី អនុប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥៣-លោក ម៉ុញ សំអឿន អនុប្រធានមណ្ឌលអប់រំកែប្រែព្រៃសរ ទី១ នាយកដ្ឋានពន្ធនាគារ
៥៤-លោក ស្រ៊ុន ឈាង អនុប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥៥-លោក ប៊ុន តារារង្សី អនុប្រធានការិយាល័យ នាយកដ្ឋានពន្ធនាគារ
៥៦-លោក តា សម្ភ័រ ប្រធានផ្នែក នាយកដ្ឋានពន្ធនាគារ
៥៧-លោក ឈួន ចាន់ថន អនុប្រធានពន្ធនាគារ ខេត្តកណ្តាល
៥៨-លោកស្រី អ៊ុំ យ៉េកឡាង អនុប្រធានការិយាល័យ ចំណោយថវិកាជាតិ
៥៩-លោក ហ៊ុំ ហាន អនុប្រធានរតនាគារ រាជធានីភ្នំពេញ

| | | | |
|---|---|---|---|
| ៦០-លោក | រ៉េអេង | សារិ | ប្រធានផ្នែកបេឡា រាជធានីភ្នំពេញ |
| ៦១-លោក | គិត | ម៉ិនះហ៊ឿន | អនុប្រធានការិយាល័យគណនេយ្យ រតនាគារជាតិ |
| ៦២-លោក | ឡាយ | គីច | អនុប្រធានការិយាល័យឃ្លាំងបេឡា រតនាគារជាតិ |
| ៦៣-លោក | ប្រាក់ | សាន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៤-លោក | អ៊ី | ថន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៥-អ្នកស្រី | អ៊ុម | ចន្ថា | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៦-លោក | ជុំ | សេ់ | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៧-លោក | ឈឹម | សម្បត្តិ | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៨-លោក | សា | ឆុន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៦៩-លោក | សេ់ | រ៉េត | នាយកអនុវិទ្យាល័យ ហ៊ុន សែន ក្រាំងគន្ធរ |
| ៧០-លោក | ជួន | ឆន | នាយករង វិទ្យាល័យ កំពង់កន្ទួត |
| ៧១-លោក | នួច | ស៊ីម | ប្រធានការិយាល័យ សុខាភិបាល |
| ៧២-លោក | យឹម | ផាត | នាយកអនុវិទ្យាល័យ ហ៊ុន សែន ដើមឫស |
| ៧៣-លោក | កែ | សារឿន | អនុប្រធានការិយាល័យអប់រំ ស្រុក |
| ៧៤-លោក | សឿង | ពិសិដ្ឋ | អនុប្រធានការិយាល័យវប្បធម៌ ស្រុក |
| ៧៥-លោក | អ៊ំ | ណារិទ្ធ | អនុប្រធានការិយាល័យពត៌មាន ស្រុក |
| ៧៦-លោក | ពេជ | រឿម | នាយកសាលាបឋមសិក្សាអន្លង់រមៀត |
| ៧៧-លោក | អ៊ុក | ម៉ិន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៧៨-លោក | សៀក | ម៉ុនលី | អធិការ នគរបាលស្រុក |
| ៧៩-លោក | អ៊ុម | សុផាត | អធិការរង នគរបាលស្រុក |
| ៨០-លោក | ណុ | ម៉ុនឆឿន | អធិការរង នគរបាលស្រុក |
| ៨១-លោក | យ៉ង់ | យ៉េត | មន្ត្រីស្រុកកណ្តាលស្ទឹង |
| ៨២-លោក | ខេម | ឆឿន | ប្រធានការិយាល័យសាធារណការស្រុក |
| ៨៣-លោក | នឹម | នឿន | អនុប្រធានការិយាល័យសាធារណការស្រុក |
| ៨៤-លោក | ឯក | ឈន | ប្រធានការិយាល័យ សេដ្ឋកិច្ចស្រុក |
| ៨៥-លោក | សាំង | សារឹម | អនុប្រធានការិយាល័យធម្មការស្រុក |
| ៨៦-លោក | មុំ | សារ៉ាត | អនុប្រធានការិយាល័យ អប់រំស្រុក |
| ៨៧-លោក | គុំ | សំអុល | អនុប្រធានការិយាល័យរដ្ឋបាលស្រុក |
| ៨៨-លោក | ម៉ុន | ម៉ន | នាយក អនុវិទ្យាល័យសៀមរាប |
| ៨៩-លោក | អ៊ុម | វិចិត្រ | នាយករង អនុវិទ្យាល័យសៀមរាប |
| ៩០-លោក | សុន | សឿន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ៩១-លោក | ហឿន | ម៉ុន្នី | អនុប្រធានការិយាល័យ អប់រំស្រុក |
| ៩២-លោក | នេព | សំនៀង | ប្រធានការិយាល័យ វប្បធម៌ស្រុក |
| ៩៣-លោក | ទ្រី | សារុន | ប្រធានការិយាល័យ ព្រៃឈើស្រុក |
| ៩៤-លោក | អ៊ួច | ធឿន | ប្រធានការិយាល័យ ពាណិជ្ជកម្មស្រុក |
| ៩៥-លោក | នៅ | សាត | ប្រធានការិយាល័យ ភូមិបាលស្រុក |
| ៩៦-លោក | អ៊ឹម | សារុម | អនុប្រធានការិយាល័យ វប្បធម៌ស្រុក |
| ៩៧-លោក | អ៊ុយ | សុន | នាយកសាលាបឋមសិក្សាព្រែកកំពិស |
| ៩៨-លោក | មុំ | វណ្ណារ៉ា | នាយកសាលាបឋមសិក្សាគោករលួស |

| | | | |
|---|---|---|---|
| ៩៩-លោក | ម៉ុក | សុធា | ប្រធានការិយាល័យសង្គមកិច្ចស្រុក |
| ១០០-លោក | អ៊ុន | ឫទ្ធី | ប្រធានការិយាល័យធនធានទឹកស្រុក |
| ១០១-លោក | ហ៊្វ | ហុក | ប្រធានការិយាល័យពន្ធដារស្រុក |
| ១០២-លោក | ឆេព | យ៉េន | នាយកវិទ្យាល័យកំពង់កន្ទួត |
| ១០៣-លោក | ជួន | សំអុន | មន្ត្រី ស្រុកកណ្តាលស្ទឹង |
| ១០៤-លោក | អ៊ុយ | នួច | ប្រធានការិយាល័យផែនការស្រុក |
| ១០៥-លោក | ប្រាក់ | ពេញ | ប្រធានការិយាល័យ ហិរញ្ញវត្ថុស្រុក |
| ១០៦-លោក | ជាំ | ស៊ីអ៊ឹម | មន្ត្រី ស្រុកកណ្តាលស្ទឹង |

**គ-មេដាយសំរឹទ្ធការងារ :**

| | | | |
|---|---|---|---|
| ១-លោក | ពេជ | សុខឆេង | មន្ត្រី ការិយាល័យ កសិកម្មស្រុក |
| ២-លោក | យិន | ពុំ | មន្ត្រី សាលាស្រុក |
| ៣-លោក | ជា | ចំនួនស្មើ | មន្ត្រី ការិយាល័យ ធនធានទឹកស្រុក |
| ៤-លោក | ឌុច | ទិមុល | មន្ត្រី ការិយាល័យ បរិស្ថានស្រុក |
| ៥-លោក | មិន | ឌី | មន្ត្រី ការិយាល័យ កសិកម្មស្រុក |
| ៦-លោក | ផេង | សារ៉ា | មន្ត្រី ការិយាល័យ អប់រំស្រុក |
| ៧-លោក | ម៉ុន | ថុល | មន្ត្រី សាលាស្រុក |
| ៨-លោក | គង់ | បូរ៉ា | គ្រូអនុវិទ្យាល័យសៀមរាប |
| ៩-លោក | ឃួត | លៀងស្រ៊ុន | គ្រូវិទ្យាល័យ កំពង់កន្ទួត |
| ១០-លោក | សួស | អាង | មន្ត្រី សាលាស្រុក |
| ១១-លោក | អួច | សោះទៀន | មន្ត្រី សាលាស្រុក |
| ១២-លោក | សឿង | វេតនា | មន្ត្រី សាលាស្រុក |
| ១៣-លោក | ហ៊ឹម | ឃាន | មន្ត្រី សាលាស្រុក |
| ១៤-លោក | ស | វ៉ន | មន្ត្រី សាលាស្រុក |
| ១៥-លោក | អ៊ឹម | សុភី | មន្ត្រី សាលាស្រុក |
| ១៦-លោក | ស្រ៊ុន | ម៉ុនចំនួ | មន្ត្រី ចូលនិវត្តន៍ |
| ១៧-លោក | ចេង | ជឹម | មន្ត្រី ចូលនិវត្តន៍ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រីបណ្ឌិត **អ៊ុ ទំនី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអគ្គលេខាធិការរងអចិន្ត្រៃយ៍ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ « **សេនា** » ប្រគេនព្រះចៅអធិការព្រះនាម **កែម ចន្ថា** ដែលបានខិតខំបិណ្ឌបាត្រចតុបច្ច័យ ដើម្បីរួមចំណែកកសាងនូវសមិទ្ធផលនានា ក្នុងវត្ត ជោតិនារាម គរ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច* ✓
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..០៩....ស.ស.រ

## សេចក្តីសំរេច
## ស្តីពី
## ការប្រគល់សិទ្ធិ

៚៚✻៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំ រេ ច

**ប្រការ ១.-** ត្រូវបានប្រគល់សិទ្ធិជូន **ឯកឧត្តម ទ៉ោ ហុងលី** អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជាអ្នកសំរបសំរួលគំរោងសិក្សាស្តីពី ការពង្រឹងមុខងារសាធារណៈ តាមរយៈការកែលំអការចំណាយ សំរាប់គ្រប់គ្រងធនធានមនុស្ស ជំនួស **ឯកឧត្តម ទ្រាក់ សុខុន** ។

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ "៣"*
- *កាលប្បវត្តិ-ឯកសារ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៩ សសរ

# សេចក្តីសំរេច

## ស្តីពី

## គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

*** ***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញអនុក្រឹត្យលេខ ៧១អនក្រ.បក. ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-យោងតាមតំរូវការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

**ប្រការ១ .-**

កែសំរួលឈ្មោះពី គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត-ក្រុង មកជា គណៈកម្មាធិការ ត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ទាំង២៤ ដូចខាងក្រោម :

១-ក្រុងភ្នំពេញ ២-ក្រុងព្រះសីហនុ

| | |
|---|---|
| ៣-ក្រុងប៉ៃលិន | ៤-ក្រុងកែប |
| ៥-ខេត្តកោះកុង | ៦-ខេត្តបាត់ដំបង |
| ៧-ខេត្តពោធិសាត់ | ៨-ខេត្តបន្ទាយមានជ័យ |
| ៩-ខេត្តឧត្តរមានជ័យ | ១០-ខេត្តព្រះវិហារ |
| ១១-ខេត្តស្ទឹងត្រែង | ១២-ខេត្តរតនៈគិរី |
| ១៣-ខេត្តមណ្ឌលគិរី | ១៤-ខេត្តក្រចេះ |
| ១៥-ខេត្តកំពង់ចាម | ១៦-ខេត្តស្វាយរៀង |
| ១៧-ខេត្តព្រៃវែង | ១៨-ខេត្តកណ្តាល |
| ១៩-ខេត្តតាកែវ | ២០-ខេត្តកំពត |
| ២១-ខេត្តកំពង់ស្ពឺ | ២២-ខេត្តកំពង់ឆ្នាំង |
| ២៣-ខេត្តកំពង់ធំ | ២៤-ខេត្តសៀមរាប |

**ប្រការ២.-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង មានសមាសភាពដូចតទៅ :

| | |
|---|---|
| -អភិបាលខេត្ត ឬ ក្រុង | ប្រធាន |
| -អភិបាលរងខេត្ត ឬ ក្រុង ១ រូប | សមាជិកអចិន្ត្រៃយ៍ |
| -ស្នងការ ឬ តំណាងនគរបាលខេត្ត ឬ ក្រុង ១ រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងយោធភូមិភាគ ១ រូប (ចំពោះខេត្តដែលមានយោធភូមិភាគឈរជើង) | សមាជិក |
| -មេបញ្ជាការ ឬ តំណាងកងនាវាចរខេមរភូមិន្ទមូលដ្ឋានដែនសមុទ្រ (ខេត្តកំពត ខេត្តកោះកុង ក្រុងកែប ក្រុងព្រះសីហនុ) ១ រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងកងនាវាចរខេមរភូមិន្ទមូលដ្ឋានដែនទន្លេ ១ រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងកងទ័ពអាកាសចរនៃកងយោធពលខេមរភូមិន្ទ ១ រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងតំបន់ប្រតិបត្តិការសឹករងខេត្ត ក្រុង ១ រូប | សមាជិក |
| -មេបញ្ជាការ ឬ តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ក្រុង ១ រូប | សមាជិក |
| -ប្រធានស្នាក់ការ គយ-រដ្ឋាករខេត្ត ក្រុង ១ រូប | សមាជិក |
| -ប្រធានសាខាកាំកុងត្រូលខេត្តក្រុង ១ រូប | សមាជិក |
| -ប្រធាន ឬ តំណាងមន្ទីរជំនាញចំណុះខេត្ត ក្រុង(មន្ទីរអប់រំយុវជន និង កីឡា មន្ទីរសុខាភិបាល មន្ទីរសង្គមកិច្ចការងារ.... ។ល។ ១ រូប | សមាជិក |

**ប្រការ៣.-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង មានភារកិច្ចដូចតទៅ :

**ក-ចំពោះខេត្ត-ក្រុង ដែលមានព្រំដែនជាប់ប្រទេសថៃ ឡាវ វៀតណាម :**

-សហប្រតិបត្តិការ និង សំរបសំរួលវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនរវាងខេត្ត-ក្រុង នៃប្រទេសជិតខាងដែលមានព្រំដែនជាប់គ្នា ។

-ធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរព័ត៌មានតាមព្រំដែន រាល់បញ្ហាដែលពាក់ព័ន្ធនឹងការចរាចរជួញដូរ ការផលិតគ្រឿងញៀន ការដាំដុះដំណាំគ្រឿងញៀន ការប្រើប្រាស់បំពានគ្រឿងញៀន និង ការចរាចរសារធាតុគីមីផ្សំ ។

-បង្កើតនីតិវិធីរួមមួយសំរាប់ទំនាក់ទំនងខាងបណ្តាញផ្លាស់ប្តូរ-ប្រមូលព័ត៌មានពីគ្នាទៅវិញទៅមក រវាងខេត្ត-ក្រុងនៃប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់គ្នា ។

-បង្កើតឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីក្នុងវិស័យផ្សេងៗ សំរាប់ការងារត្រួតពិនិត្យគ្រឿងញៀនដោយឈរលើស្មារតីគិតគូរដល់ផលប្រយោជន៍រួម ។

-រៀបចំឱ្យមានកម្មវិធីជួបប្រជុំជាប្រចាំជាមួយភាគីនៃខេត្តជាប់ព្រំដែននៃប្រទេសជិតខាង ឱ្យបានទៀងទាត់ដើម្បីពិភាក្សា និង កសាងផែនការសកម្មភាពរួមគ្នា និង ពង្រីកកិច្ចសហប្រតិបត្តិការនេះ ។

ក្រៅពីភារកិច្ចខាងលើ ខេត្ត-ក្រុងដែលជាប់ព្រំដែនក៏ត្រូវបំពេញភារកិច្ចដូចខេត្ត-ក្រុង នៅក្នុងផ្ទៃប្រទេសដែលមានចែងអំពីភារកិច្ចក្នុងចំណុច"ខ"ខាងក្រោមនេះដែរ ។

**ខ-ចំពោះខេត្ត ក្រុង នៅក្នុងផ្ទៃប្រទេស :**

-ត្រូវកសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនថ្នាក់ខេត្ត-ក្រុងដោយយកចិត្តទុកដាក់សំខាន់ :

.ការងារពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់អំពី វិធានការស៊ើបអង្កេតស្រាវជ្រាវរកឧក្រិដ្ឋជនផលិត ជួញដូរគ្រឿងញៀន សារធាតុគីមីផ្សំ ដាំដុះដំណាំគ្រឿងញៀន និង នីតិវិធីតុលាការ ។

.ការងារអប់រំ បង្ការ ការពារ ការប្រើបំពានគ្រឿងញៀន តាមរយៈយុទ្ធនាការឃោសនាផ្សព្វផ្សាយធ្វើឱ្យមានការយល់ដឹងជាទូទៅអំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។

.រៀបចំឱ្យមានកម្មវិធី និង កន្លែងសំរាប់ព្យាបាលអ្នកញៀនគ្រឿងញៀននៅក្នុងខេត្ត-ក្រុងរបស់ខ្លួន ។

-ត្រូវរៀបចំអោយមានប្រព័ន្ធផ្លាស់ប្តូរព័ត៌មានពីខេត្ត-ក្រុងមួយទៅខេត្ត-ក្រុងមួយ រាល់បញ្ហាដែលពាក់ព័ន្ធនឹងការផលិត ការដាំដុះ ការប្រើបំពាន ការចរាចរជួញដូរគ្រឿងញៀន និង សារធាតុគីមីផ្សំ ។

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ត្រូវប្រមូលផ្តុំការដឹកនាំដល់មន្ត្រីដែលស្ថិតក្នុងវិស័យផ្សេងៗដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យគ្រឿងញៀនសំដៅធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**គ-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង :**

-រាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំ និង រាយការណ៍ភ្លាមៗជាបន្ទាន់ក្នុងករណីពិសេស មក អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់អគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ប្រការ៤.-**

ទីតាំងរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង អាស្រ័យដោយប្រធានគណៈកម្មាធិការ ជាអ្នកសំរេច ។

**ប្រការ៥.-**

គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយជាសេនាធិការក្នុងការដឹកនាំ គ្រប់គ្រង លើកផែនការ តាមដាន វាយតំលៃការអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សមាជិកអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអ្នកទទួលខុសត្រូវលើការងាររបស់លេខាធិការដ្ឋាននេះ ។

**ប្រការ៦.-**

ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ត្រូវធ្វើការកែសំរួល ឬ បំពេញបន្ថែមនូវសមាសភាពសមាជិករបស់ខ្លួនដូចក្នុង " ប្រការ២ " និងកំណត់ភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដូចក្នុង" ប្រការ៣ " នៃសេចក្តីសំរេចនេះ ។

អភិបាលខេត្ត-ក្រុងដែលជាម្ចាស់អាណាប័ក ត្រូវម្ចាស់ការក្នុងការរៀបចំបង្កើតឱ្យមានកញ្ចប់ថវិកាដោយឡែក សំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**ប្រការ៧.-**

សេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត លេខ៣៨សសរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ សេចក្តីសំរេចលេខ៨៥សសរ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ សេចក្តីសំរេចលេខ២៦សសរ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងនាវាចរខេមរភូមិន្ទមូលដ្ឋានដែនសមុទ្រ មេបញ្ជាការកងទ័ពអាកាសចរនៃកងយោធពលខេមរភូមិន្ទ អភិបាលខេត្ត-ក្រុង ស្នងការនគរបាលខេត្ត-ក្រុង មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង មេបញ្ជាការកងរាជអាវុធហត្ថខេត្ត-ក្រុង ទីចាត់ការគយ-រដ្ឋាករ ក្រសួងពាណិជ្ជកម្ម(នាយកដ្ឋានកាំកុងត្រូល) មន្ទីរជំនាញចំណុះខេត្ត-ក្រុង អង្គភាពក្នុងវិស័យផ្សេងៗដែលពាក់ព័ន្ធការត្រួតពិនិត្យគ្រឿងញៀន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

"ដូចប្រការ៨"

- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០ សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការទប់ស្កាត់អំពើអនាធិបតេយ្យនៅ

## តំបន់ឆ្នេរសមុទ្រ ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_ យោងអនុសាសន៍សម្ដេចនាយករដ្ឋមន្ត្រី ឆ្នាំ ២០០០ សំរាប់ប្រជាជនដែលរស់នៅតំបន់ទំនប់រលក

_ យោងកំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអន្តរក្រសួង និង គណៈកម្មាធិការរៀបចំសោភ័ណភាពក្រុង ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

_ ដើម្បីធានាការគ្រប់គ្រង និង ប្រើប្រាស់តំបន់ឆ្នេរសមុទ្រអោយមានចីរភាព

## សំរេច

**ប្រការ ១** : ត្រូវបញ្ឈប់ជាបន្ទាន់ នូវសកម្មភាពបំពានច្បាប់នៅតំបន់ឆ្នេរសមុទ្រក្រុងព្រះសីហនុ ដែលបានបង្កការប៉ះពាល់បំផ្លិចបំផ្លាញបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ នៅតាមចំណុចដូចខាងក្រោម ៖

១_ការចាក់ដីចូលសមុទ្រ ០២ កន្លែង នៅតំបន់ឆ្នេររាម ភូមិអូរ សង្កាត់រាម ខណ្ឌព្រៃនប់ ។

២_ការចាក់ដីចូលសមុទ្រនៅភូមិទំនប់រលក (តំបន់ឡូទីកត្រី) ត្រង់ចំណុច $A_1$ $A_2$ $A_3$ $A_4$ តាមប្លង់របស់ក្រុមការងារសាលាក្រុងព្រះសីហនុ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ និង ០១ កន្លែងនៅតំបន់ឆ្នេរព្រែកព្រែង (ទល់មុខស្ថានីយ៍បូមទឹក) ។

**ប្រការ ២** : ចំពោះដីដែលបានចាក់ចូលសមុទ្រទាំងអស់ ដូចបានរៀបរាប់ក្នុងប្រការ ១ ខាងលើ អាជ្ញាធរក្រុងព្រះសីហនុត្រូវគ្រប់គ្រងដីនោះទុកប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ សរណន

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ២០០៤

# សារាចរណែនាំ

## ស្តីពី

## ការអនុញ្ញាតអោយរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទ ដឹកភ្ញៀវទេសចរបរទេសចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬ ឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

កន្លងមក ដោយផ្អែកលើមូលដ្ឋានសន្តិភាព សន្តិសុខ និងសុវត្ថិភាពសាធារណៈនៅទូទាំងប្រទេសមានស្ថិរភាព រាជរដ្ឋាភិបាលបាន និងកំពុងខិតខំជំរុញកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍យ៉ាងខ្លាំងក្លា ដោយអនុវត្តគោលនយោបាយបើកចំហជើងមេឃ ផ្លូវសមុទ្រ ផ្លូវទន្លេ និង បានបើកច្រកទ្វារព្រំដែនអន្តរជាតិថ្មីៗថែមទៀត ជាមួយបណ្តាប្រទេសជិតខាង ដើម្បីបង្កលក្ខណៈងាយស្រួលដល់លំហូរនៃភ្ញៀវទេសចរបរទេស អោយចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជាមានចំនួនកាន់តែកើនឡើងជាលំដាប់។

វិស័យទេសចរណ៍បានបង្ហាញយ៉ាងច្បាស់នូវតួនាទីរបស់ខ្លួនជាឧស្សាហកម្មមួយ ដែលមានការលូតលាស់ជាងគេបង្អស់ និងបានក្លាយជាមុខព្រួញយ៉ាងសំខាន់នៃកំលាំងសេដ្ឋកិច្ចតំបន់ ពិភពលោក ក៏ដូចជានៅកម្ពុជាក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។ ចំណូលដែលបានមកពីវិស័យទេសចរណ៍ បានជួយដល់ការអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិ តាមរយៈប្រាក់ចំណូលដោយផ្ទាល់ និងប្រាក់ចំណូលដោយប្រយោល ពិសេស គឺឱកាសផ្តល់ការងារដល់ប្រជាពលរដ្ឋ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ភ្ញៀវទេសចរបរទេសដែលចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជា តាមច្រកទ្វារព្រំដែនអន្តរជាតិដោយប្រើមធ្យោបាយរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទមកកាន់គោលដៅរមណីយដ្ឋានទេសចរណ៍នានា ជាពិសេសការមកទស្សនាប្រាង្គប្រាសាទអង្គរវត្ត ខេត្តសៀមរាប ប្រាង្គប្រាសាទនានា រមណីយដ្ឋានប្រវត្តិសាស្ត្រ ទីវត្តអារាម ឧទ្យានជាតិ ទេសភាព តំបន់ខ្ពង់រាប តំបន់ភ្នំ តំបន់បឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរសមុទ្រ នៃបណ្តាខេត្ត-ក្រុង នៅជួបការលំបាកនៅឡើយ។

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរបរទេស និងកែលំអការងារខាងលើ អោយមានភាពរលូន ឆាប់រហ័ស រាជរដ្ឋាភិបាលដាក់ចេញនូវការណែនាំ និងវិធានការមួយចំនួនដូចខាងក្រោម :

១-អនុញ្ញាតឱ្យរថយន្តចង្កូតស្តាំ និងចង្កូតឆ្វេងគ្រប់ប្រភេទដឹកភ្ញៀវទេសចរបរទេសចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

២-រថយន្តដឹកភ្ញៀវទេសចរបរទេសគ្រប់ប្រភេទ ដែលត្រូវបានអនុញ្ញាតឱ្យចូលបណ្តោះអាសន្ន និងចេញទៅវិញ ឬឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា លុះត្រាតែរថយន្តទាំងនោះបានបំពេញលក្ខខណ្ឌដូចខាងក្រោម :

-មានប័ណ្ណធានារ៉ាប់រងស្របច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

-មានលក្ខណៈបច្ចេកទេសត្រឹមត្រូវ

-មានផ្លាកលេខសំគាល់ និង

-មានប័ណ្ណសំគាល់រថយន្ត ដែលចេញដោយប្រទេសសាមី ។

៣-អ្នកបើកបររថយន្តដឹកភ្ញៀវទេសចរបរទេស ត្រូវមានប័ណ្ណបើកបរដែលមានសុពលភាពតាមប្រភេទរថយន្ត និងត្រូវមានបទពិសោធន៍ក្នុងការបើកបរប្រកាន់ស្តាំ និងការធ្វើចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤-ក្រសួងសាធារណការ និងដឹកជញ្ជូន រៀបចំដាក់ផ្លាកសញ្ញាបង្ហាញផ្លូវ និងចម្ងាយផ្លូវ ពីគោលដៅមួយទៅគោលដៅមួយឱ្យបានច្បាស់លាស់ ចាប់ពីច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកបើកបរដឹកភ្ញៀវទេសចរបរទេសបានស្គាល់ភូមិសាស្ត្រនៃខេត្ត-ក្រុង ស្រុក-ខណ្ឌ ទីប្រជុំជន និងតំបន់ទេសចរណ៍សំខាន់ៗ ពេលចូលមកព្រះរាជាណាចក្រកម្ពុជា ។

៥-ម្ចាស់រថយន្តដឹកភ្ញៀវទេសចរបរទេសទាំងអស់ ត្រូវបំពេញបែបបទគយតាមនីតិវិធីជាធរមាន នៅទីស្នាក់ការគយ និងរដ្ឋាករ ប្រចាំនៅច្រកទ្វារព្រំដែនអន្តរជាតិពាក់ព័ន្ធ និងត្រូវយកចេញទៅវិញនូវរថយន្តដែលបានចូលបណ្តោះអាសន្នស្របតាមការអនុញ្ញាត ។

៦-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ជាបន្ទាន់នូវនីតិវិធីគយសាមញ្ញដោយឡែកមួយពាក់ព័ន្ធនឹងបញ្ហានេះ ដោយកំណត់ឱ្យបានច្បាស់ពីពេលមួយទៅពេលមួយ នូវប្រភេទរថយន្តដែលពុំត្រូវឱ្យកក់ប្រាក់ពន្ធ ឬអាករ ប៉ុន្តែត្រូវអោយមានឯកសារភ្ជាប់នានាសំរាប់ការត្រួតពិនិត្យគយ និង រដ្ឋាករ ការដាក់ឱ្យប្រើប្រាស់នូវប្រតិវេទន៍គយតូច សំរាប់ការចូលបណ្តោះអាសន្ន ឬ ឆ្លងកាត់ ដើម្បីជំរះបញ្ជីពេលរថយន្តចេញទៅវិញ ។

៧-ការខកខានមិនបានយកចេញទៅវិញនូវរថយន្តទាំងនោះ បុគ្គលជាប្រតិវេទករត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីប្រធានស័ក្តិ ។

៨-គ្រប់ភ្នាក់ងាររដ្ឋបាលសារពើពន្ធ ដែលបំពេញភារកិច្ចប្រចាំការនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវតែខិតខំជួយសម្រួលឱ្យភ្ញៀវទេសចរបរទេសចេញ-ចូលព្រះរាជាណាចក្រកម្ពុជា បានកាន់តែងាយស្រួល និងស្របច្បាប់ ។

៩-អភិបាលខេត្ត-ក្រុង ដែលមានទីតាំងការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវអនុវត្តនូវការធ្វើរបាយការណ៍ ស្ដីពីលទ្ធផល នៃបរិមាណអ្នកដំណើរ និងភ្ញៀវទេសចរឆ្លងកាត់ច្រកទ្វារចេញ-ចូល មកទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ។

ទទួលបន្ទុកអនុវត្តសារាចរណែនាំនេះ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីខេត្ត-ក្រុង ត្រូវចាត់ចែងអនុវត្តតាមតួនាទីភារកិច្ចរៀងៗខ្លួន ឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
  សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

លេខ : ០០១ សសរ

## សេចក្ដីសំរេច

## ស្ដីពី ក្រុមការងារគ្រប់គ្រងដីរដ្ឋ

៙ * ៙

## ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៨ អ.ន.ក្រ/ប.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងឯកសារបឋមស្ដីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០០២
- យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាគោលនយោបាយដីធ្លី ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងដីរដ្ឋ

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារគ្រប់គ្រងដីរដ្ឋ ក្នុងក្របខ័ណ្ឌនៃការងាររបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោកស្រីបណ្ឌិត **អ៊ូ ទំឌី** | អគ្គលេខាធិការរងអចិន្ត្រៃយ៍នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី | ប្រធាន |
| ២- លោក **ឈី សាវុធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣- លោក **ទ្រាក់ អង្គារ៉ា** | ប្រធាននាយកដ្ឋានស្រាវជ្រាវបទប្បញ្ញត្តិ នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៤- លោក **ហ៊ុយ ផាវ់** | អនុប្រធាននាយកដ្ឋានអភិរក្ស នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

| | | |
|---|---|---|
| ៣- លោក **ហុង ណារិត** | អនុប្រធាននាយកដ្ឋានផែនការស្ថិតិ សហប្រតិបត្តិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤- លោកស្រី **អ៊ុក សីលា** | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន | សមាជិក |
| ៥- លោក **គុយ សរើម** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោកវរ.ឯក **ខឹម សុខ** | នាយករងនាយកដ្ឋានវិស្វកម្ម នៃក្រសួងការពារជាតិ | សមាជិក |
| ៧- លោក **សរ សិទ្ធី** | អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨- លោក **ស៊ុខ សុគន់** | អនុប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- លោក **ឈុំ ខុង** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១០- លោក **ហែម ស៊ីទន** | ប្រធានការិយាល័យសារពើភ័ណ្ឌ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក **ចណ្ណ សំណាង** | ប្រធានការិយាល័យធនធានធម្មជាតិ និងសម្បទាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- លោកស្រី **នន់ ការី** | សមាជិកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សា គោលនយោបាយដីធ្លី | សមាជិក |
| ១២-លោក **សោម ស៊ីវដា** | សមាជិកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សា គោលនយោបាយដីធ្លី | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ២** : ក្រុមការងារនេះ មានទីតាំងអចិន្ត្រៃយ៍នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ( ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) និង មានភារកិច្ច :

- ពិនិត្យ លើកយោបល់ ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី លើសេចក្តីព្រាងឯកសារគោលនយោបាយ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងដីរដ្ឋ ដែលអគ្គលេខាធិការក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានសម្របសម្រួល និងសហការជាមួយអ្នកជំនាញការអន្តរជាតិ រៀបចំចងក្រងឡើង
- កសាងផែនការសកម្មភាពអន្តរក្រសួង និងគំរោងគម្រូការ ដើម្បីដំណើរការការធ្វើអត្តសញ្ញាណកម្ម ការកសាងផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- សម្របសម្រួលក្នុងការផ្តល់ពត៌មានតាមរូបថតពីលើអាកាស និងធនធានផ្សេងៗទៀតពីក្រសួងនានា និងពីមូលដ្ឋាន ក្នុងការធ្វើអត្តសញ្ញាណកម្ម ការកសាងផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

- រៀបចំការប្រជុំពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ និងធ្វើការបូកសរុបលទ្ធផលការងារ រាយការណ៍ជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**ប្រការ ៣ :** ក្រុមការងារនេះ មានការគាំទ្រផ្នែកបច្ចេកទេស ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការសម្របសម្រួលផ្នែករដ្ឋបាលទូទៅពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**ប្រការ ៤ :** សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុម ។

**ប្រការ ៥ :** នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី នាយកគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី លោក លោកស្រី ដូចមានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៤

**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

អ៊ឹម ឈុនលិម

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចប្រការ៥ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០៧០ MOC / M 2004

ភ្នំពេញ,ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រិត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រិត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះតាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ០១៧ MOC / M 2004 ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០៤ ។
- យោងតាមការចាំបាច់នៃការងារ ។

## សំរេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់និមួយ ១ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៤ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៤ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តន៍ប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

ចំលងជូន :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
  "ដើម្បីជ្រាបជាពត៌មាន"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*File : Quota Tender Result, February 27, 2004*

ANNEX - A

ក្រសួង ពាណិជ្ជកម្ម , MINISTRY OF COMMERCE

11:04 AM 02-27-2004

**MINISTRY OF COMMERCE**
TENDER of QUOTA

**TENDER of QUOTA**
**February 27, 2004**

| ID | COMPANY NAME | 334/634 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 29,000 | $2.00 | | | |
| 1 | W&D GARMENT | 5,800 | $5.40 | $31,320.00 | $3,132.00 | $28,188.00 |
| 2 | CINKAMP APPAREL | 5,800 | $5.20 | $30,160.00 | $3,016.00 | $27,144.00 |
| 3 | GREAT LANCELOT INTERNATIONAL | 520 | $5.20 | $2,704.00 | $270.40 | $2,433.60 |
| 4 | OCEANIC GARMENT CAMBODIA CO.,LTD | 5,800 | $5.20 | $30,160.00 | $3,016.00 | $27,144.00 |
| 5 | B&N GARMENT | 4,169 | $5.00 | $20,845.00 | $2,084.50 | $18,760.50 |
| 6 | GOLD-KAMVIMEX GARMENT | 1,667 | $5.00 | $8,335.00 | $833.50 | $7,501.50 |
| 7 | KBAL KOAH GARMENT | 409 | $5.00 | $2,045.00 | $204.50 | $1,840.50 |
| 8 | CHU HSING GMT | 4,835 | $5.00 | $24,175.00 | $2,417.50 | $21,757.50 |
| | **TOTAL** | **29,000** | | **$149,744.00** | **$14,974.40** | **$134,769.60** |

| ID | COMPANY NAME | 335/635 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 11,000 | $2.00 | | | |
| 1 | JIANSU DIAO GARMENT | 2,200 | $12.20 | $26,840.00 | $2,684.00 | $24,156.00 |
| 2 | CHEER VIEW TEXTILE CAMBODIA | 2,200 | $12.00 | $26,400.00 | $2,640.00 | $23,760.00 |
| 3 | KOG VENG GARMENT | 2,200 | $12.00 | $26,400.00 | $2,640.00 | $23,760.00 |
| 4 | KIN TAI GARMENT CO.,LTD | 2,200 | $12.00 | $26,400.00 | $2,640.00 | $23,760.00 |
| 5 | YOU CHENG GARMENT | 1,000 | $11.60 | $11,600.00 | $1,160.00 | $10,440.00 |
| 6 | KENNETEX INTERNATIONAL (CAMBODIA) | 600 | $11.20 | $6,720.00 | $672.00 | $6,048.00 |
| 7 | QMI INDUSTRIAL CO., LTD | 600 | $11.20 | $6,720.00 | $672.00 | $6,048.00 |
| | **TOTAL** | **11,000** | | **$131,080.00** | **$13,108.00** | **$117,972.00** |

| ID | COMPANY NAME | 338/339 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 600,000 | $2.00 | | | |
| 1 | PAK SHUN KNITTING FACTORY | 50,000 | $6.20 | $310,000.00 | $31,000.00 | $279,000.00 |
| 2 | GOLDFAME GARMENT | 50,000 | $5.80 | $290,000.00 | $29,000.00 | $261,000.00 |
| 3 | JUNE TEXTILES CO.,LTD | 70,000 | $5.80 | $406,000.00 | $40,600.00 | $365,400.00 |
| 4 | HECTER CAMBODIA GARMENT | 10,000 | $5.20 | $52,000.00 | $5,200.00 | $46,800.00 |
| 5 | YUNG WAH GARMENT | 120,000 | $5.20 | $624,000.00 | $62,400.00 | $561,600.00 |
| 6 | WING HANG ( CAMBODIA) GARMENT CO.,LTD | 10,000 | $5.00 | $50,000.00 | $5,000.00 | $45,000.00 |
| 7 | K&P CAMBODIA GARMENT LTD. | 20,000 | $4.80 | $96,000.00 | $9,600.00 | $86,400.00 |
| 8 | ARCHID GARMENT | 30,000 | $4.80 | $144,000.00 | $14,400.00 | $129,600.00 |
| 9 | SPLENDID CHANCE GARMENT | 12,450 | $4.80 | $59,760.00 | $5,976.00 | $53,784.00 |
| 10 | FRANCO KNITTING GARMENT FACTORY LTD | 10,000 | $4.80 | $48,000.00 | $4,800.00 | $43,200.00 |
| 11 | SUN SHINE CO.,LTD | 80,000 | $4.80 | $384,000.00 | $38,400.00 | $345,600.00 |
| 12 | YUBIN SERVICE CO.,LTD | 50,000 | $4.80 | $240,000.00 | $24,000.00 | $216,000.00 |
| 13 | GLADPEER GARMENT | 20,000 | $4.60 | $92,000.00 | $9,200.00 | $82,800.00 |
| 14 | CHEAN PING GARMENT | 10,000 | $4.60 | $46,000.00 | $4,600.00 | $41,400.00 |
| 15 | TAI YAR GARMENT INDUSTRY CO.,LTD | 30,000 | $4.60 | $138,000.00 | $13,800.00 | $124,200.00 |
| 16 | SAMETEX GARMENT CAMBODIA CO.LTD | 3,162 | $4.40 | $13,912.80 | $1,391.28 | $12,521.52 |
| 17 | SUNTEX PTE, LTD | 10,839 | $4.40 | $47,691.60 | $4,769.16 | $42,922.44 |
| 18 | BEST HONOUR INTERNATIONAL GARMENT | 10,839 | $4.40 | $47,691.60 | $4,769.16 | $42,922.44 |
| 19 | VINSTAR GARMENTS INDUSTRY CO.,LTD | 2,710 | $4.40 | $11,924.00 | $1,192.40 | $10,731.60 |
| | **TOTAL** | **600,000** | | **$3,100,980.00** | **$310,098.00** | **$2,790,882.00** |


Ministry of Commerce # 20 A & B Preah Norocom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) ... 58 Facsimile (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) ... 21223 Facsimile (855-23) 426396

ANNEX - A

ក្រសួង ពាណិជ្ជកម្ម . MINISTRY OF COMMERCE 11:54 AM

**MINISTRY OF COMMERCE**
TENDER of QUOTA

**TENDER of QUOTA**
**February 27, 2004**

| ID | COMPANY NAME | 340/640 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL 10% | TOTAL90% |
| | | 200,000 | $1.00 | | | |
| 1 | GOLDEN JET CAMBODIA GARMENT LTD | 8,000 | $1.00 | $8,000.00 | $800.00 | $7,200.00 |
| 2 | MSI GARMENT | 35,000 | $1.00 | $35,000.00 | $3,500.00 | $31,500.00 |
| 3 | SOUTH BAY ENTERPRISE CO.LTD | 20,000 | $1.00 | $20,000.00 | $2,000.00 | $18,000.00 |
| 4 | JRB ACTION TEXTILES & CLOSING LTD | 10,000 | $1.00 | $10,000.00 | $1,000.00 | $9,000.00 |
| 5 | GDM ENTERPRISE CO.,LTD | 10,000 | $1.00 | $10,000.00 | $1,000.00 | $9,000.00 |
| 6 | ROO HSING GARMENT CO.,LTD | 5,000 | $1.00 | $5,000.00 | $500.00 | $4,500.00 |
| 7 | QMI INDUSTRIAL CO., LTD | 400 | $1.00 | $400.00 | $40.00 | $360.00 |
| | TOTAL | 88,400 | | $88,400.00 | $8,840.00 | $79,560.00 |

| ID | COMPANY NAME | 347/348/647/648 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL 10% | TOTAL90% |
| | | 700,000 | $3.00 | | | |
| 1 | PAK SHUN KNITTING FACTORY | 88,030 | $13.20 | $1,161,996.00 | $116,199.60 | $1,045,796.40 |
| 2 | JUNE TEXTILES CO.,LTD | 30,000 | $12.80 | $384,000.00 | $38,400.00 | $345,600.00 |
| 3 | GOLDFAME GARMENT | 100,000 | $12.60 | $1,260,000.00 | $126,000.00 | $1,134,000.00 |
| 4 | TRINUNGGAL KOMARA GARMENT | 120,000 | $12.20 | $1,464,000.00 | $146,400.00 | $1,317,600.00 |
| 5 | KIN TAI GARMENT CO.,LTD | 60,000 | $12.00 | $720,000.00 | $72,000.00 | $648,000.00 |
| 6 | TAI YANG ENTERPRISE CO.,LTD | 140,000 | $12.00 | $1,680,000.00 | $168,000.00 | $1,512,000.00 |
| 7 | OCEAN GARMENT CO.,LTD | 50,000 | $11.20 | $560,000.00 | $56,000.00 | $504,000.00 |
| 8 | KENNETEX INTERNATIONAL (CAMBODIA) | 35,000 | $11.20 | $392,000.00 | $39,200.00 | $352,800.00 |
| 9 | HECTER CAMBODIA GARMENT | 3,498 | $11.00 | $38,478.00 | $3,847.80 | $34,630.20 |
| 10 | KOG VENG GARMENT | 3,498 | $11.00 | $38,478.00 | $3,847.80 | $34,630.20 |
| 11 | ROO HSING GARMENT CO.,LTD | 69,974 | $11.00 | $769,714.00 | $76,971.40 | $692,742.60 |
| | TOTAL | 700,000 | | $8,468,666.00 | $846,866.60 | $7,621,799.40 |

| ID | COMPANY NAME | 352/652 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL 10% | TOTAL90% |
| | | 100,000 | $0.40 | | | |
| 1 | DOUBLE WIN INTERNATIONAL CORP | 20,000 | $1.20 | $24,000.00 | $2,400.00 | $21,600.00 |
| 2 | JIANSU DIAO GARMENT | 1,340 | $1.20 | $1,608.00 | $160.80 | $1,447.20 |
| 3 | VIVATINO DESIGN CAMBODIA PTE | 20,000 | $1.00 | $20,000.00 | $2,000.00 | $18,000.00 |
| 4 | KINGSLAND GARMENT | 20,000 | $1.00 | $20,000.00 | $2,000.00 | $18,000.00 |
| 5 | MAHATTAN TEXTILE GARMENT CORP | 3,705 | $0.80 | $2,964.00 | $296.40 | $2,667.60 |
| 6 | TRICO GARMENT | 1,544 | $0.80 | $1,235.20 | $123.52 | $1,111.68 |
| 7 | JOYFUL GARMENT | 3,088 | $0.80 | $2,470.40 | $247.04 | $2,223.36 |
| 8 | SPLENDID CHANCE GARMENT | 6,176 | $0.80 | $4,940.80 | $494.08 | $4,446.72 |
| 9 | SUPPREM CHOICE CAMBODIA GARMENT | 2,532 | $0.80 | $2,025.60 | $202.56 | $1,823.04 |
| 10 | UNITED ETERNITY GARMENT | 6,176 | $0.80 | $4,940.80 | $494.08 | $4,446.72 |
| 11 | FOUR SEASON GARMENT | 6,176 | $0.80 | $4,940.80 | $494.08 | $4,446.72 |
| 12 | NEW ORIENT GARMENT | 3,088 | $0.80 | $2,470.40 | $247.04 | $2,223.36 |
| 13 | UNITED ARTS GARMENT | 4,631 | $0.80 | $3,704.80 | $370.48 | $3,334.32 |
| 14 | MJTS APPAREL CO.,LTD | 1,544 | $0.80 | $1,235.20 | $123.52 | $1,111.68 |
| | TOTAL | 100,000 | | $96,536.00 | $9,653.60 | $86,882.40 |

*File : Quota Tender Result, February 27, 2004* Page 2 of 3

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 818993 - 881223 Facsimile: (855-23) 426396

ANNEX - A

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 11:54 AM 02/27/2004

**MINISTRY OF COMMERCE**

TENDER of QUOTA

**TENDER of QUOTA**
**February 27, 2004**

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 150,000 | $1.00 | | | |
| 1 | SAMETEX GARMENT CAMBODIA CO.LTD | 5,000 | $1.40 | $7,000.00 | $700.00 | $6,300.00 |
| 2 | WINNER GARMENT MANUFACTURING | 8,550 | $1.20 | $10,260.00 | $1,026.00 | $9,234.00 |
| 3 | M&V INTERNATIONAL MFG | 5,000 | $1.20 | $6,000.00 | $600.00 | $5,400.00 |
| 4 | FRANCO KNITTING GARMENT FACTORY LTD | 20,000 | $1.20 | $24,000.00 | $2,400.00 | $21,600.00 |
| 5 | CHEAN PING GARMENT | 30,000 | $1.20 | $36,000.00 | $3,600.00 | $32,400.00 |
| 6 | SABRINA GARMENT | 30,000 | $1.20 | $36,000.00 | $3,600.00 | $32,400.00 |
| 7 | NAN KUANG GARMENT | 3,662 | $1.00 | $3,662.00 | $366.20 | $3,295.80 |
| 8 | DOUBLE WIN INTERNATIONAL CORP | 3,662 | $1.00 | $3,662.00 | $366.20 | $3,295.80 |
| 9 | JRB ACTION TEXTILES & CLOSING LTD | 7,324 | $1.00 | $7,324.00 | $732.40 | $6,591.60 |
| 10 | S.H INTERNATIONAL CO.,LTD | 3,662 | $1.00 | $3,662.00 | $366.20 | $3,295.80 |
| 11 | CAMBO FASHION | 10,985 | $1.00 | $10,985.00 | $1,098.50 | $9,886.50 |
| 12 | YUNG WAH GARMENT | 10,985 | $1.00 | $10,985.00 | $1,098.50 | $9,886.50 |
| 13 | YOU CHENG GARMENT | 185 | $1.00 | $185.00 | $18.50 | $166.50 |
| 14 | SUN SHINE CO.,LTD | 10,985 | $1.00 | $10,985.00 | $1,098.50 | $9,886.50 |
| | **TOTAL** | **150,000** | | **$170,710.00** | **$17,071.00** | **$153,639.00** |

| | | | |
|---|---|---|---|
| **Sub-TOTAL** | **$12,206,116.00** | **$1,220,611.60** | **$10,985,504.40** |


Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 818853 / 881223 Facsimile (855-23) 426396

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០០៤

ក្រសួងទេសចរណ៍

លេខ ០២៤ ទសចរ

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំល្បែងប្រជាប្រិយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ឆ្នាំវក ឆស័ក ពុទ្ធសករាជ ២៥៤៨ ត្រូវនឹងថ្ងៃទី ១៣-១៤-១៥ ខែមេសា ឆ្នាំ២០០៤ ដើម្បីទាក់ទាញ និងបំរើដល់ភ្ញៀវទេសចរ ជាតិ និងអន្តរជាតិ

អនុលោមតាមស្មារតីនៃអង្គប្រជុំសន្និបាតបូកសរុបការងារទេសចរណ៍រយះពេល ០៤ឆ្នាំ ១៩៩៨-២០០២ និងទិសដៅការងារឆ្នាំ ២០០៣ ស្តីពីសកម្មភាពឆ្នាំទស្សនាកម្ពុជា យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៤ ស្តីពីការបង្កើតព្រឹត្តិការណ៍ផ្សេងៗដើម្បីទាក់ទាញ និងបំរើភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងក្នុងគោលបំណងដើម្បីអោយពិធីបុណ្យចូលឆ្នាំខ្មែរខាងមុខជាព្រឹត្តិការណ៍មួយដ៏សប្បាយរីករាយ អធិកអធម និងជាឱកាសមួយដើម្បីបង្ហាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ អំពីវប្បធម៌ ប្រពៃណីទំនៀមទំលាប់ខ្មែរ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់មន្ទីរទេសចរណ៍គ្រប់ខេត្ត-ក្រុងដូចតទៅ :

១- ត្រូវយកចិត្តទុកដាក់រៀបចំអោយមានលេងល្បែងប្រជាប្រិយទូទៅ ដូចជា ចោលឈូង លាក់កន្សែង បោះអង្គុញ ទាញព្រ័ត្រ ដណ្តើមស្លឹកឈើ ស្តេចចង់ ចាប់កូនខ្លែង រាំវង់ ...។ល។ និងល្បែងប្រជាប្រិយតាមតំបន់នីមួយៗ ដទៃផ្សេងទៀត ទៅតាមប្រពៃណីទំនៀមទំលាប់ខ្មែរ រៀបចំអោយមាន ការតាំងពិព័រណ៍ និងបង្កើតផ្សារពោត ដើម្បីដាក់លក់ផលិតផលកសិកម្ម សិប្បកម្ម វត្ថុអនុស្សាវរីយ៍ ផ្លែឈើ ម្ហូបអាហារ នំចំណីខ្មែរអោយមានលក្ខណៈសំបូរបែប ។ល។

២- នៅពេលរាត្រីត្រូវរៀបចំសំដែងសិល្បៈចំរុះ តែត្រូវបំផុសអោយមានការសំដែងសិល្បៈ និងរបាំប្រពៃណីផ្សេងៗ អោយបានផុលផុស ព្រមទាំងមានបង្ហោះគោម បាញ់កាំជ្រួច ។

៣- ចំពោះទីកន្លែងគួរសហការពិគ្រោះសុំយោបល់ជាមួយអាជ្ញាធរខេត្ត-ក្រុង និងស្ថាប័នពាក់ពន្ធ័ដើម្បីជ្រើសយកទីប្រជុំជនរមណីយដ្ឋានសំខាន់ៗ ដែលមានបរិវេណធំទូលាយ មានម្លប់ត្រជាក់ និងជាទីពេញនិយម ពីសំណាក់ភ្ញៀវទេសចរជាតិ

និងអន្តរជាតិដើម្បីរៀបចំ ។

៤- រាល់ការរៀបចំត្រូវយកចិត្តទុកដាក់អំពីការគ្រប់គ្រងអោយបានល្អប្រសើរ ធានាអោយបាននូវសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់ មានអនាម័យល្អ ហើយហាមដាច់ខាតនូវការលេងល្បែងស៊ីសងដែលនាំអោយខូចរបៀបរៀបរយ រំខាន ដល់សេចក្តីសុខសាន្ត ការសប្បាយរបស់ប្រជាជន និងប្រាសចាកពីប្រពៃណីវប្បធម៌ ដ៏ល្អផូរផង់របស់ជាតិយើង ។

ទទួលបានការណែនាំខាងលើនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុង សហការអោយបានល្អជាមួយអាជ្ញាធរខេត្ត-ក្រុង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធទាំងអស់ដើម្បីអនុវត្តអោយបានល្អប្រសើរ និងធានាបានសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពខ្ពស់ ។៥

ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

រដ្ឋលេខាធិការ

ថោង ខុន

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទិស្តីការគណៈរដ្ឋមន្ត្រី
  "គោរពជូនជ្រាប"
- អាជ្ញាធរគ្រប់ខេត្តក្រុង
  "ដើម្បីសហការ"
- មន្ទីរទេសចរណ៍គ្រប់ខេត្ត-ក្រុង
  "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ.....០៧០.............ធ.ធ.ស(ប្រ)

## ប្រកាស

### ស្តីពីការបង្កើតថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រ.ក.ត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២.នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា
- យោងសំណើសុំបើកថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ លេខ ៣៤២ មធស.ក.ធ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ របស់មន្ទីរធម្មការ និងសាសនា ខេត្តកំពង់ឆ្នាំង
- យោងចំណារឯកភាព លេខ ១១១២ ស.រ.ស.ល ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់អភិបាលខេត្តកំពង់ឆ្នាំង ។

## សម្រេច

ប្រការមួយ : បង្កើតថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិនៅ **ពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម** ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : ពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំ របស់មន្ទីរធម្មការ និងសាសនាខេត្តកំពង់ឆ្នាំង និងការណែនាំមុខជំនាញបច្ចេកទេស របស់អគ្គនាយកដ្ឋានពុទ្ធិកសិក្សា នៃក្រសួងធម្មការនិងសាសនា

ប្រការ ៣ : ពុទ្ធិកវិទ្យាល័យនេះ ត្រូវចាប់បើកថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំសិក្សា ២០០៤-២០០៥ តទៅ ។

ប្រការ ៤ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានពុទ្ធិកសិក្សា នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ការិយាល័យបុគ្គលិក និងមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ឆ្នាំង មានភារកិច្ចរៀងៗខ្លួន អនុវត្តន៍សេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងប្រគេន-ជូន**

- ថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និង កីឡា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តកំពង់ឆ្នាំង ដើម្បីថ្វាយ ជូនជ្រាបជាពត៌មាន
- ដូចប្រការ ៤ ដើម្បីអនុវត្ត

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

ជា-សាវឿន

ព្រះរាជាណាចក្រកម្ពុជា

ទីស្តីការ ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ និង ក្រសួងពាណិជ្ជកម្ម

លេខៈ ០១ ប្រក.កយ.ពណ.២០០៤

# ប្រកាសរួម

## ស្តីពី

## ការដាក់អោយប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើស ស្តីពីគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ជូនមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម

************

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម /០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និង សេវា

-បានឃើញព្រះរាជក្រមលេខ នស/រកម /០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣ ប្រកាសអោយប្រើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០២ ស្តីពីវិសោធនកម្ម មាត្រា៣៦ មាត្រា៣៨ មាត្រា៥០ និង មាត្រា៥១ នៃច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ

-បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ-បក ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ-បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីអនាម័យ នៃម្ហូបអាហារ សំរាប់មនុស្ស

-បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ-បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការធ្វើ អាជីវកម្ម អំបិលអ៊ីយ៉ូដ

-បានឃើញប្រកាសលេខ ០១២ ពណ.បណ.ប្រក ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

-តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម លេខ ២៦៣៤ MoC/M2003 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

# សំរេច

**ប្រការ ១ :** ត្រូវបានទទួលស្គាល់ដោយច្បាប់ជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញភារកិច្ចជាមន្ត្រី នគរបាលយុត្តិធម៌ ដល់មន្ត្រីក្រសួងពាណិជ្ជកម្ម រួមមាន :

-ប្រធាន អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)

-ប្រធាន អនុប្រធានការិយាល័យរដ្ឋបាល

-ប្រធាន អនុប្រធានការិយាល័យអង្កេត

-ប្រធាន អនុប្រធានមន្ទីរពិសោធន៍

-ប្រធាន អនុប្រធានការិយាល័យបច្ចេកទេស

-ប្រធាន អនុប្រធានសាខាអនុវត្តភារកិច្ចត្រួតពិនិត្យគ្រប់ខេត្ត-ក្រុង ស្ថិតក្រោមអំណាចផ្ទាល់របស់ នាយកដ្ឋានកាំកុងត្រូល

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហ្វេរ៍ណេ អាហ្វេរ៍ណេ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) និងក្រោមការដឹកនាំ សម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់អោយមានប្រសិទ្ធភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**ប្រការ ២ :** អនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្មដូចមានចែងក្នុងប្រការ១ ខាងលើប្រើប្រាស់ជាផ្លូវការ នូវគំរូសំណុំលិខិតដោះស្រាយបទល្មើសរួមមាន :

-កំណត់ហេតុត្រួតពិនិត្យជាក់ស្តែង

-កំណត់ហេតុបណ្តឹង របាយការណ៍

-កំណត់ហេតុបទល្មើស

-កំណត់ហេតុបទល្មើសជាក់ស្តែង

-កំណត់ហេតុឆែកឆេរ

-កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាង

-កំណត់ហេតុនៃការប្រគល់ត្រឡប់វិញនូវឯកសារដែលបានដកហូត

-កំណត់ហេតុលើកលែងការឃាត់ទុក

-កំណត់ហេតុស្តីពីការចាត់ចែងឱ្យមានលក្ខណៈសារស្រេច ( ផលិតផលទំនិញ)

-កំណត់ហេតុស្តីពីការប្តូរទិសដៅ ( ផលិតផលទំនិញ)

-កំណត់ហេតុរឹបអូស ឬកំទេចចោល

-កំណត់ហេតុសេចក្តីពោលអះអាងនានា( ប្រកាសហេតុ)

-កំណត់ហេតុសាកសួរពត៌មាន

-កំណត់ហេតុចុះពិនិត្យទីកន្លែងកើតហេតុ

-កំណត់ហេតុយកចំលើយសាក្សី

-កំណត់ហេតុសួរចំលើយជនល្មើស

-កំណត់ហេតុចាប់ខ្លួន-ឃាត់ខ្លួនជនល្មើស

-កំណត់ហេតុយកគំរូតាងមកវិភាគ

-កំណត់ហេតុប្រគល់-ទទួលគំរូតាង

-កំណត់ហេតុស្តីពីការបដិសេធមិនទទួលទុកគំរូតាង

-របាយការណ៍សំយោគ

-ពាក្យបណ្តឹងផ្ញើជូនព្រះអាជ្ញាអមតុលាការ ខេត្ត-ក្រុង

-កំណត់ហេតុស្តីពីការប្រគល់-ទទួលវត្ថុតាង

-កំណត់ហេតុស្តីពីការប្រគល់-ទទួលជនល្មើស

-សលាកប័ត្រទោសទ័ណ្ឌ

-ព្រឹត្តិប័ត្រពតិមានជនល្មើស

-ដីកាបញ្ជូន ឬដីកាអម ទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

ដូចមានភ្ជាប់មកជាមួយនេះ ដើម្បីអោយមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម ងាយស្រួលបំពេញបែបបទប្រតិបត្តិការរបស់ខ្លួនអោយបានសមស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមានបញ្ញត្តិ ។

**ប្រការ ៣ :** មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម ដូចមានចែងក្នុងប្រការ ១ ខាងលើ តុលាការគ្រប់ខេត្ត-ក្រុង និងអយ្យការអមតុលាការខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមគំរូសំណុំលិខិតដោះស្រាយបទល្មើស ដូចមានចែងក្នុងប្រការ ២តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤ :** ប្រកាសនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែ កុម្ភៈ ឆ្នាំ ២០០៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

នាង.ស៊ីផុង

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ចម_ប្រសិទ្ធ

**ចំលងជូនៈ**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-គ្រប់ក្រសួង ស្ថាប័ន

-អភិបាលខេត្ត - ក្រុង

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៣ "ដើម្បីអនុវត្ត "

-ឯកសារ កាលប្បវត្តិ